00438953

ERN/N: D337

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 28 / 01 / 2010
ម៉ោង (Time/Heure): 13:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

# ការិយាល័យសហចៅក្រមស៊ើបអង្កេត

BUREAU DES CO-JUGES D'INSTRUCTION
OFFICE OF THE CO-INVESTIGATING JUDGES

ថ្ងៃទី២៧ ខែមករា ឆ្នាំ ២០០៩

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 28 / 01 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

ជូន៖ គ្រប់ភាគីពាក់ព័ន្ធ
អង្គភាពជនរងគ្រោះ

ពី៖ ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Marcel Lemonde
សហចៅក្រមស៊ើបអង្កេត

ECCC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

**សាធារណៈ**

**កម្មវត្ថុ៖ ការដាក់ពាក្យបណ្តឹងធម្មតា និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

**យោង៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស**

១. ការដាក់ពាក្យបណ្តឹងធម្មតា និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ស្ថិតនៅក្រោមបណ្តុំវិធានគតិយុត្តមួយពិសេស ដែលមានលក្ខណៈជាច្រើនខុសពីរបបគតិយុត្តដែលអនុវត្តចំពោះកិច្ចស៊ើបសួរ[1]។

---

[1] សូមមើល វិធាន ២៣ និង ៤៩ នៃវិធានផ្ទៃក្នុង អ.វ.ត.ក។ សូមមើលផងដែរ ការពន្យល់បង្ហាញមាននៅក្នុងយុត្តិសាស្ត្របារាំង, សាលដីកាតុលាការព្រហ្មទណ្ឌ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០, *Cass. crim., 26 sept. 2000 : Juris-Data n°*

២. ដោយយល់ថាវាជាការចាំបាច់ក្នុងការធ្វើការបញ្ជាក់ខ្លះមួយចំនួន ពាក់ព័ន្ធនឹងបែបបទអនុវត្តក្នុងការដាក់ពាក្យបណ្តឹងនានា អនុស្សារណៈនេះមានគោលដៅផ្តល់ព័ត៌មានចាំបាច់មួយចំនួនដល់អង្គភាពជនរងគ្រោះ ដើម្បីផ្តល់ព័ត៌មានដល់ដើមបណ្តឹងធម្មតា និងដើមបណ្តឹងរដ្ឋប្បវេណី កំនត់ពេលវេលាអនុវត្ត និងជូនដំណឹងដល់ភាគី។

៣. អនុលោមតាមវិធាន ២៣.៣ នៃវិធានផ្ទៃក្នុង អ.វ.ត.ក ជនរងគ្រោះមានរយៈពេល ១៥ថ្ងៃ បន្ទាប់ពីការជូនដំណឹងដល់ភាគីទាំងអស់អំពីការបញ្ចប់កិច្ចស៊ើបសួរ ដើម្បីធ្វើការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជាមួយនឹងអង្គភាពជនរងគ្រោះ។ នៅក្នុងសំនុំរឿងកំពុងស៊ើបអង្កេតនេះ រយៈពេលនេះគឺគិតត្រឹមថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០ ត្រឹមម៉ោង ១៩ គត់។

៤. ទំរង់បែបបទចូលរួម -ជាដើមបណ្តឹងរដ្ឋប្បវេណីក្តី និងជាបណ្តឹងធម្មតាក្តី- ដែលបានធ្វើឡើងជាមួយអង្គភាពជនរងគ្រោះ ត្រូវបានចាត់ទុកថាបានធ្វើឡើងជាមួយនឹងស្ថាប័នតុលាការដែលមានសមត្ថកិច្ច។

## ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

៥. ចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលទទួលបាន មុនការបរិច្ឆេទកំណត់ខាងលើ អង្គភាពជនរងគ្រោះត្រូវបញ្ជូនមកសហចៅក្រមស៊ើបអង្កេត៖

ក. នូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលពាក់ព័ន្ធនឹងសំនុំរឿង ០០២ ក្នុងរយៈពេលពីរខែបន្ទាប់ពីផុតរយៈពេលដែលបានកំនត់នៅក្នុង កថាខណ្ឌ៣ នៃអនុស្សារណៈនេះ។ ដូចនេះគឺត្រឹមថ្ងៃទី២៩ ខែមិនា ឆ្នាំ២០១០។

---

*2000-006258 ; Bull. crim., n° 276*៖ ការដាក់ពាក្យជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានធ្វើឡើងតាមនៅក្នុងដំណាក់កាលជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរមិនចាត់ទុកជាកិច្ចស៊ើបសួរនោះទេ។

00438955

ឯកសារ: D337

៥. នូវរាល់ព័ត៌មានបន្ថែមនានាដើម្បីបំពេញការខ្វះខាតមាននៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលបានធ្វើឡើង ក្នុងរយៈពេលបីខែបន្ទាប់ពីផុតរយៈពេលដែលបានកំនត់នៅក្នុង កថាខណ្ឌ៣ នៃអនុស្សរណៈនេះ។ ពោលគឺត្រឹមថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១០។

៦. អនុលោមតាមវិធាន២៣ នៃវិធានផ្ទៃក្នុង អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតនឹងបញ្ចូលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ទៅក្នុងសំនុំរឿង ក្រោមលេខឯកសារ D22។

៧. ដីកាពាក់ព័ន្ធនឹងការទទួលយកដើមបណ្ដឹងរដ្ឋប្បវេណីនឹងត្រូវបានសម្រេច ជាបន្តបន្ទាប់និងយ៉ាងយូរបំផុតនៅពេលចេញដីកាដំណោះស្រាយ។

៨. រាល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលបានធ្វើឡើងក្រោយរយៈពេលកំនត់នៅក្នុងវិធាន ២៣.៣ នៃវិធានផ្ទៃក្នុង អ.វ.ត.ក នឹងត្រូវបដិសេធចោល។

៩. ដើមបណ្ដឹងណាដែលអះអាងថាបានទទួលរងព្យសនកម្មពីអង្គហេតុនៃបទល្មើសដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ អ.វ.ត.ក ប៉ុន្តែពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ខ្លួនត្រូវបានសម្រេចថាមិនអាចទទួលយក នៅក្នុងសំនុំរឿង ០០២ ទេនោះ។ ពាក្យបណ្ដឹងទាំងនោះនឹងត្រូវស្ថិតនៅក្នុងសំនុំរឿងដដែល ក្រោមលេខឯកសារ D230/2 ក្នុងឋានៈជាពាក្យបណ្ដឹងធម្មតា លើកលែងតែមានការសម្រេចផ្សេងពីនេះរបស់សហព្រះរាជអាជ្ញា។

## ពាក្យបណ្ដឹងធម្មតា

១០. ចំពោះបណ្ដឹងធម្មតា សហចៅក្រមស៊ើបអង្កេតសូមរំលឹកថា វាអាស្រ័យទៅលើសហព្រះរាជអាជ្ញាធ្វើការសម្រេចការកំនត់ពេលវេលាណាមួយ ដើម្បីដាក់ពាក្យបណ្ដឹង នៅក្នុងក្របខ័ណ្ឌសំនុំរឿង០០២[2]។

---

[2] សេចក្ដីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០៖
http://www.eccc.gov.kh/khmer/cabinet/press/111/ECCC_OCP-PR_27Jan2010_Kh_.pdf

១១. ប្រសិនបើសហព្រះរាជអាជ្ញាសម្រេចបញ្ជូនបណ្តឹងធម្មតានោះមកសហចៅក្រមស៊ើបអង្កេត ដោយអនុលោមតាមវិធាន ៤៩ នៃវិធានផ្ទៃក្នុង អ.វ.ត.ក បណ្តឹងទាំងនោះនឹងត្រូវដាក់ចូលទៅក្នុងសំនុំរឿង ក្រោមលេខឯកសារ D230/1 និង D230/2 ដោយពិចារណាថាតើបណ្តឹងទាំងនោះវាជួយ ឬមិនជួយបង្ហាញអង្គហេតុដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។